ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សេចក្តីប្រកាសព័ត៌មាន

ថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលព័ត៌មានថា មានការនាំចូលជីដែលមានលាយកន្ទុយបារីមកកាន់ព្រះរាជាណាចក្រកម្ពុជា។

ចំពោះករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការប្រកាសដូចតទៅ៖

១-និរាករណ៍លិខិតអនុញ្ញាតនាំចូល នាំចេញជីកសិកម្ម ដែលកន្លងមកបានផ្តល់ឲ្យក្រុមហ៊ុន **ប៉ែន លឹម គ្រឿងគ្រុប** មានអាសយដ្ឋានផ្ទះលេខ១៤ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកងទី១ ខណ្ឌចម្ការមន រាជធានីភ្នំពេញ ចាប់ពីពេលនេះតទៅ។

២-មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចធ្វើការប្រមូលទំនិញដែលមានកន្ទុយបារីទាំងនោះ ដើម្បីយកមកគ្រប់គ្រងនិងចាត់វិធានការតាមនីតិវិធីជាបន្ត។

៣-មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីវឌ្ឍនភាពនៃការងារដែលពាក់ព័ន្ធនឹងករណីខាងលើ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B.V.D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320